# អ្នកនាំសារ
## The Messenger

51

ថ្ងៃទី ០១-១៥ ខែសីហា ឆ្នាំ២០០៧- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ



# ចូរយើងបម្រើគ្នាដោយចិត្តសប្បុរស !



យុវជនជុំគិរីជួយក្មេងៗខ្វះភាពកក់ក្ដៅ ទំព័រ ៩



របាំទេពអប្សរ ទំព័រ ១០

ការធ្វើជីកំប៉ុស្ដ ទំព័រ ១១

## ព្រះរាជជីវប្រវត្តិសង្ខេបនៃ ព្រះមហាវីរក្សត្រ នរោត្តម សីហនុ



Photo: DR

ទ្រង់ប្រសូតនៅថ្ងៃទី៣១ តុលា ឆ្នាំ១៩២២ នៅរាជធានីភ្នំពេញ គឺជាបុត្រារបស់ព្រះមហាក្សត្រនរោត្តម សុរ៉ាម្រិត និងម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរតន៏។

ឆ្នាំ១៩៤១ : ព្រះអង្គឡើងគ្រងរាជសម្បត្តិ។

ឆ្នាំ១៩៤៦ : ព្រះអង្គចូលរួមកិច្ចប្រជុំជាលើកទី១ ជាមួយប្រធានាធិបតីបារាំង ឆាលដឺ ហ្គោ Charles de Gaulle និងក៏ជាកាលបរិច្ឆេទដែល ព្រះអង្គចាប់ផ្តើមចូលរៀននៅសាលាយោធាសូមៀ Saumur របស់ប្រទេសបារាំងផងដែរ។

ឆ្នាំ១៩៥៣ : ព្រះអង្គសម្រេចបានព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យភាព ដោយប្រទេសបារាំងបានយល់ព្រមផ្តល់ឯករាជ្យពេញលេញក្រោយពីការដាក់អាណានិគមមកលើប្រទេសកម្ពុជាអស់ជិតមួយសតវត្សរ៍។

ឆ្នាំ១៩៥៤ : ឯកឧត្តមនេរុ នាយករដ្ឋមន្ត្រីនៃប្រទេសឥណ្ឌា បានមកធ្វើទស្សនកិច្ចជាលើកដំបូងមកកាន់ព្រះរាជាណាចក្រកម្ពុជា។

ឆ្នាំ១៩៥៥ : ព្រះអង្គដាក់រាជសម្បត្តិ ថ្វាយព្រះរាជបិតារបស់ព្រះអង្គ ព្រះមហាក្សត្រនរោត្តម សុរ៉ាម្រិត។ ព្រះអង្គបង្កើតក្រុមចលនាសង្គមរាស្ត្រនិយម និងព្រះអង្គបានធ្វើទស្សនកិច្ចជាលើកទី១ របស់ព្រះអង្គទៅកាន់ប្រទេសចិន ដោយបានទទួលពីសំណាក់ឯកឧត្តមជូ អេនឡាយ Chou En -lai ។

ឆ្នាំ១៩៥៦ : ព្រះអង្គធ្វើទស្សនកិច្ចទៅប្រទេសយូហ្គោស្លាវីជួបប្រជុំលើកដំបូងជាមួយលោកប្រធានាធិបតីទីតូ និងក៏ធ្វើការខ្លះជាមួយលោកប្រធានម៉ៅ សេទុង នៃប្រទេសចិន ដោយបានចុះហត្ថលេខាលើធម្មនុញ្ញលើកទី៥ ប្រកាសពីអ្វីដែលបានកើតឡើងជាមួយជាតិសាសន៍ដែលមិននៅក្នុងជួរជាមួយ។

តទៅលេខក្រោយ...



## ថ្ងៃអាទិត្យទី១៩ ក្នុងរដូវធម្មតា (ថ្ងៃទី ១២សីហា ឆ្នាំ២០០៧)

"ចូរត្រៀមខ្លួនជានិច្ច" (លូកា ១២,៣២-៤៨)

នៅកម្ពុជា ក្រុមគ្រីស្តបរិស័ទខ្លះតែងប្រកាសថា : "ព្រះគ្រីស្តយាងមកវិញហើយ" ឬ "ព្រះអង្គយាងមកដល់ហើយ" បណ្តាលឱ្យអ្នកស្រុកភ្ញើល និងរាជរដ្ឋាភិបាលក៏ចេញសារាចរហាមមិនឱ្យប្រកាសពាក្យនេះទៀត។ យើងជាគ្រីស្តបរិស័ទកាតូលិកមិនត្រូវរវល់អំណាចស្តីបន្ទោសទេ ពីព្រោះតាមអត្ថបទគម្ពីរដំណឹងល្អថ្ងៃនេះ ព្រះយេស៊ូដាស់តឿនយើងឱ្យរង់ចាំព្រះអង្គយាងមក។ ព្រះអង្គមិនកំណត់ថ្ងៃទេ ហើយក៏គ្មាននរណាដឹងថា ព្រះអង្គយាងមកពេលណាដែរ។ ព្រះយេស៊ូសព្វព្រះហឫទ័យរំឭកយើងថា ព្រះអង្គយាងមកគឺដូចជាចោរប្លន់នៅពេលយប់ គឺនៅពេលដែលយើងមិននឹកស្មានសោះ។ តាមពិតព្រះអង្គយាងមកនៅពេលណាមនុស្សម្នាក់មកជួបយើង។ តាមជំនឿយើង ទោះជាគ្រីស្តបរិស័ទក្តី ពុទ្ធបរិស័ទក្តី អ្នកមិនកាន់សាសនាក្តី គឺសុទ្ធតែជាបុត្រធីតារបស់ព្រះបិតា និងជារូបតំណាងព្រះយេស៊ូផ្ទាល់។ ប្រសិនបើយើងទទួលអ្នកដទៃ និងបម្រើគេ យើងពិតជាទទួល និងបម្រើព្រះយេស៊ូដែលយាងមក។

ហេតុនេះបានជាយើងត្រូវត្រៀមខ្លួនជានិច្ច មានជំនឿ មើលអ្នកដទៃតាមរបៀបព្រះអង្គទតមើលគេ។ យើងទទួលព្រះយេស៊ូដែលយាងមក ដោយនឹកដល់ព្រះអង្គជានិច្ច យកចិត្តទុកដាក់កសាងសង្គមដោយយុត្តិធម៌ យកចិត្តទុកដាក់រកយុត្តិធម៌ជូនអ្នកក្រីក្រ ចែកចាយទ្រព្យសម្បត្តិតាមសមត្ថភាពខ្លួន និងមានចិត្តស្មោះនឹងប្រពន្ធកូន-ល- ទុកជាសញ្ញាសំគាល់អំពីសម្ពន្ធមេត្រីរវាងព្រះជាម្ចាស់ និងមនុស្សលោក។ ព្រះគ្រីស្តយាងមកក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ដោយសារតែយើងរស់នៅតាមរបៀបរបស់ព្រះអង្គ។ សូមប្រុងស្មារតីនឹកទទួលព្រះគ្រីស្តដែលយាងមកឥឡូវនេះ។

## ថ្ងៃអាទិត្យទី ២០ ក្នុងរដូវធម្មតា (ថ្ងៃទី ១៩ សីហា ឆ្នាំ២០០៧)

"ខ្ញុំនាំការបាក់បែកមក" (លូកា ១២,៤៩-៥៣)

យើងជាជនជាតិកម្ពុជា ចូលចិត្តសេចក្តីសុខសាន្ត និងមិនចង់ឱ្យនរណាម្នាក់ទាស់នឹងយើងទេ។ ប៉ុន្តែក្នុងអត្ថបទគម្ពីរដំណឹងល្អយើងអានថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលថា ព្រះអង្គមិននាំសេចក្តីសុខសាន្តមកទេ ព្រះអង្គនាំការបាក់បែកវិញ។ គួរឱ្យឆ្ងល់យ៉ាងខ្លាំងអំពីព្រះបន្ទូលរបស់ព្រះយេស៊ូនេះ។

លោកលូកានិពន្ធគម្ពីរ នៅពេលរដ្ឋអំណាចរ៉ូម៉ាំងបៀតបៀនធ្វើបាបគ្រីស្តបរិស័ទ។ គេចាប់ចងគ្រីស្តបរិស័ទទៅឃុំឃាំង និងកាប់សម្លាប់ទៀតផង។ ដូច្នេះរស់នៅធ្វើជាគ្រីស្តបរិស័ទមិនស្រួលទេ។ ក្នុងអត្ថបទនេះ លោកលើកទឹកចិត្តគ្រីស្តបរិស័ទឱ្យដឹងថា គង់តែមានអ្នក គេជំទាស់នឹងអ្នកមានជំនឿលើព្រះគ្រីស្ត ព្រោះតែមានជំនឿប្លែកពីអ្នកដទៃ គឺត្រូវបាក់បែកពីគេម្យ៉ាង។

នៅកម្ពុជាយើងក៏ដូច្នេះដែរ គ្រីស្តបរិស័ទជាអ្នកបែកបាក់ ម្យ៉ាងពីក្រុមគ្រួសារ ត្រូវគេចោទថា ខ្លួនក្បត់សាសនាជាតិក្បត់សាសនាដូនតា និងជាកូនអកតញ្ញូ។ល។ យើងដឹងច្បាស់ថា ពាក្យចោទទាំងនោះ មិនពិតទេ គឺបណ្តាលមកពីគេមិនស្គាល់គ្រីស្តសាសនាយើង ហើយខ្លាចអ្នកមានជំនឿថ្មីនោះ។

ទោះជាយ៉ាងណាក៏ដោយ ក៏យើងត្រូវដឹងថា របៀបរស់នៅរបស់យើង ប្លែកពីរបៀបរស់នៅរបស់អ្នកឯទៀតៗ យើងពុំស្វែងរកតែទ្រព្យសម្បត្តិលោកីយ៍តាមលទ្ធិសម្ភារៈនិយមទំនើប នៅជុំវិញយើងឡើយ។ យើងក៏មិនឆ្លៀតឱកាសកេងប្រវ័ញ្ច មិនភ្លើតភ្លើនវក់តាមតណ្ហាទេ គឺខិតខំរកយុត្តិធម៌ឱ្យអ្នកក្រីក្រ និងទាមទារសេរីភាព។ល។ ប្រសិនបើគ្មាននរណាជំទាស់នឹងយើង នោះបានសេចក្តីថា យើងរស់នៅដូចគេ និងរស់នៅតាមរបៀបលោកីយ៍ ហើយមិនរស់នៅតាមរបៀបព្រះយេស៊ូទេ។ យើងប្រៀបបានដូចជាមេនៅក្នុងម្សៅ ដែលនាំឱ្យម្សៅទាំងមូលដោរឡើង។ ដូច្នេះប្រសិនយើងមិនធ្វើឱ្យម្សៅដោរឡើងនោះទេ តើយើងគឺជាគ្រីស្តបរិស័ទឧណ្ហ? ទេដឹង?

សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា !





## តើមានរូបអ្វីសម្រាប់លេខនេះ...?



ក្រុមអ្នកចូលរួមទទួលការអប់រំជំនឿនៅព្រះសហគមន៍សៀមរាបដែលណែនាំដោយលោក ញៀន សុខ រៀង រាល់ថ្ងៃអាទិត្យ។ ការអប់រំជំនឿគឺជាភារកិច្ចជាការមួយដ៏សំខាន់ក្នុងការបន្តជំនឿអំពីព្រះយេស៊ូដល់បងប្អូនស្វែងរក។

លោកឪពុកហេរី : ទោះបីមានជំងឺ និងអស់កម្លាំងក្នុងការបំពេញកិច្ចការព្រះសហគមន៍យ៉ាងច្រើនក៏ដោយ លោកនៅតែបញ្ចេញនូវស្នាមញញឹមយ៉ាងរាក់ទាក់ចំពោះអ្នកជំងឺ កុមាររងគ្រោះ និងយុវជន-នារីដែលត្រូវការជំនួយពីលោក





ព្រះវិហារសន្តសិលានៅព្រះសហគមន៍ពោធិ៍ចិនតុងនៅភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ សម្ពោធកាលពីថ្ងៃទី១ ខែកក្កដាកន្លងទៅ ដែលចំណាយទឹកប្រាក់ជាង ១៥ម៉ឺនដុល្លារ។

Photographed by L. Sovanna & S. Philong



## បទអន្តរាគមន៍ លោកអូលីវីយេ

តពីលេខមុន...

ក្នុងលិខិត Eccleesia in Asia របស់សម្តេចប៉ាប យ៉ូហាន ប៉ូល ទី២ សរសេរថា : "ប្រកាសដំណឹងល្អប្រៀបដូចចែកចាយពន្លឺនៃជំនឿក្នុងព្រះយេស៊ូគ្រីស្ត។"

អំណោយទានដែលយើងទទួល ត្រូវចែកចាយដល់ប្រជារាស្ត្រនៅអាស៊ី (Eas10)។ ហើយគឺជាជីវិតព្រះយេស៊ូដែលយើងត្រូវចែកចាយ !

និទានជីវិតព្រះយេស៊ូគឺនិទានអំពីជីវិតផ្ទាល់ព្រះអង្គ គឺឱ្យព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺព្រះសហគមន៍សម័យនេះ។ តួអង្គសំខាន់ដើម្បីប្រកាសដំណឹងល្អគឺព្រះវិញ្ញាណដ៏វិសុទ្ធដូចមានការរំឭកក្នុង Redemptoris Missio(Chap.3)។

ព្រះវិញ្ញាណដ៏វិសុទ្ធនិទានជីវិតព្រះយេស៊ូក្នុងជីវិតយើង និងក្នុងជីវិតរបស់ព្រះសហគមន៍ ដូចព្រះយេស៊ូមានព្រះបន្ទូលអំពីព្រះបរមកិច្ចនៃព្រះវិញ្ញាណ (យ៉ូហាន ១៦,១៣-១៥)។

១៣ កាលណាព្រះវិញ្ញាណនៃសេចក្តីពិតយាងមកដល់ ព្រះអង្គនឹងនាំអ្នករាល់គ្នាឱ្យស្គាល់សេចក្តីពិតគ្រប់ជំពូក ត្បិតសេចក្តីផ្សេងៗ ព្រះអង្គថ្លែងមិនចេញពីព្រះអង្គផ្ទាល់ទេ គឺព្រះអង្គថ្លែងតែសេចក្តីដែលទ្រង់សណ្តាប់ឮ ព្រមទាំងមានព្រះបន្ទូលប្រាប់ឱ្យអ្នករាល់គ្នាដឹងអំពីហេតុការណ៍ដែលកើតមាននៅថ្ងៃខាងមុខ។ ១៤ ព្រះអង្គនឹងសម្តែងសិរីរុងរឿងរបស់ខ្ញុំ ព្រះអង្គទទួលនូវសេចក្តីទាំងអស់ពីខ្ញុំ យកមកប្រាប់អ្នករាល់គ្នា។ ១៥ អ្វីៗដែលព្រះបិតាមានទាំងប៉ុន្មានសុទ្ធតែជារបស់ខ្ញុំទាំងអស់។ ហេតុនេះហើយបានជាខ្ញុំពោលថា ព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំ យកមកប្រាប់អ្នករាល់គ្នា។"

ដូច្នេះអ្វីទៅជាភារៈកិច្ចរបស់ព្រះសហគមន៍ និងរបស់យើងទាំងអស់គ្នាសព្វថ្ងៃនេះ ? តើយើងត្រូវនិទានជីវិតព្រះយេស៊ូនៅទីនេះ នៅពេលនេះក្នុងប្រទេសកម្ពុជាយ៉ាងដូចម្តេច ?

តទៅលេខក្រោយ...

# ពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សានៅសាលាផ្ទុនបូស្កូនារី

កាលពីថ្ងៃសៅរ៍ ទី២១ កក្កដា នៅសាលាផ្ទុនបូស្កូផ្នែកនារីទីក្រុងភ្នំពេញ មានរៀបចំពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនដល់សិស្សនារី ជំនាន់ទី១៣ ១០៥នាក់ ក្រោមការចូលរួមរបស់លោក គីកេ ជាអភិបាលភូមិភាគបាត់ដំបង កញ្ញា សេង ធារី នាយិកាព្រឹត្តិបត្រអភិវឌ្ឍសង្គមកម្ពុជា ភ្ញៀវជាតិអន្តរជាតិ មាតាបិតា អាណាព្យាបាល រួមនិងយុវសិស្សប្រមាណជាជាង ៣០០នាក់។

កញ្ញាសេងធារី នាយិកាព្រឹត្តិបត្រអង្គការអភិវឌ្ឍសង្គមកម្ពុជា រំឭកយុវនារីទទួលវិញ្ញាបនបត្រ ថាជីវិតតែងជួបឧបសគ្គ ប៉ុន្តែយើងអាចផ្ទេរឧបសគ្គនេះឱ្យទៅជាឱកាសសម្រាប់ខ្លួនយើងបាន។ សូមកុំអស់សង្ឃឹម និងសូមមានមោទនភាព ចំពោះអ្វីដែលមាន។ នេះមិនមែនជាថ្ងៃបញ្ចប់ទេ តែវាជាថ្ងៃដែលត្រូវចាប់ផ្តើមជីវិតក្នុងសង្គមការងារ។

កញ្ញាសុវណ្ណ សារ៉េត តំណាងយុវនារីទទួលវិញ្ញាបនបត្រ និយាយថា ពួកនាងទទួលបានជោគជ័យជាគុណសម្បត្តិរបស់បងស្រី និងអ្នកគ្រូ ដែលដូចជាអ្នកម្តាយទីពីរ បានផ្តល់ភាពកក់ក្តៅ និងអប់រំឱ្យស្គាល់អំពីតម្លៃជីវិត និងឱ្យចេះរិះគិតពីអនាគតខ្លួនអ្នកដទៃ និងគ្រួសារទៀតផង។

ចំណែកបងស្រីលីហ្សា ចន នាយិការងសាលាផ្ទុនបូស្កូផ្នែកនារីនៅទួលគោក ក៏ជឿជាក់ថា យុវនារីបញ្ចប់ការសិក្សាពិតជាអាចប្រឈមមុខនឹងបញ្ហាជួបប្រទះក្នុងជីវិតរបស់ពួកគេជាក់ជាមិនខាន។

កែវ កញ្ញា



Photo: K. Kaghna

## ក្រុមបងស្រីអ្នកគង្វាលសប្បុរសលើកតម្លៃការងារ

ម៉ោងប្រមាណជា ៦ល្ងាច មានភ្លៀងធ្លាក់រលឹមស្រិចៗ កញ្ញាកក្កដា អ្នកស្ម័គ្រចិត្តជួយក្រុម បងស្រីអ្នកគង្វាលសប្បុរស និងមិត្តភ័ក្ត ៣-៤នាក់ទៀតតែងមកហាងមួយនៅក្នុងក្រុងព្រះសីហនុជារៀងរាល់ថ្ងៃ។ ជាធម្មតានាង និងមិត្តៗទៅទីនោះដើម្បីបង្រៀនភាសាអង់គ្លេស និងវិជ្ជាផាត់មុខដល់ស្ត្រីបម្រើស្រាបៀរ។

កញ្ញាកក្កដាប្រាប់ថា ការងារនេះលំបាកណាស់។ ជាមួយស្ត្រីដែលរកស៊ីនៅបា នាងពិបាកទាក់ទងពួកគេ និងជាមួយម្ចាស់ហាងផ្ទាល់ ដោយពួកគេខ្លាចប៉ះពាល់នឹងការរកស៊ី។ កញ្ញាវ៉ត្ត អ្នកស្ម័គ្រចិត្តមួយរូបដែរនោះ និយាយថា : “ទោះបីមានការលំបាកយ៉ាងណា ខ្ញុំពេញចិត្តនឹងការងារនេះ ព្រោះខ្ញុំក៏ជាស្ត្រីខ្មែរម្នាក់ដែរ។ ខ្ញុំចង់ផ្តល់ជំនាញដែលខ្ញុំមានជួយដល់ស្ត្រីទាំងនោះ គឺដើម្បីឱ្យពួកគាត់អាចផ្លាស់ប្តូរមុខរបររបស់ពួកគាត់។”

ប្រធានក្រុមបងស្រី នៃអ្នកគង្វាលសប្បុរសធម៌ មីហែរលលូបប៉េស មានប្រសាសន៍ថា : “ខ្ញុំគ្មានការលំបាកក្នុងការងារនេះនោះទេ។ ការងារខ្ញុំគឺបង្រៀនពួកគេ ឱ្យស្គាល់អំពីតម្លៃការងារ។” នេះគឺជាការងារយ៉ាងសំខាន់ ដែលបងស្រីទទួលពួកគេដោយគ្មានល័ក្ខខ័ណ្ឌអ្វីទាំងអស់។

សំណាងគឺជាស្ត្រីបម្រើការងារក្នុងបា ជាង២ឆ្នាំហើយ។ នាងនិយាយថា នាងទទួលការបង្រៀនភាសាអង់គ្លេសអំពីក្រុមបងស្រី។ នាងមានចិត្តសប្បាយណាស់ដែលអាចធ្វើទំនាក់ទំនងជាមួយភ្ញៀវបរទេស។ នាងបន្ថែមទៀតថា : “ខ្ញុំចង់ធ្វើការងារមួយយ៉ាងសមរម្យហើយបើសិនជាអាចខ្ញុំចង់មានហាងមួយដោយខ្លួនឯង។”

ហ៊ិន វ៉ាន់

## ចាសចម្រៀងចេញថ្មី!

មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក មានចេញផ្សាយនូវស៊ីឌីចម្រៀង វ៉ុលថ្មី វ៉ុលទី៦ ដែលក្នុងនោះ មានការពិពណ៌នាអំពីព្រះនាងម៉ារីឡើងស្ថានបរមសុខ និងចម្រៀងកោតសរសើរព្រះនាង។ ស៊ីឌីចម្រៀងនេះមាន ១២បទ។ តម្លៃលក់គឺ ៨ ០០០រៀលតែប៉ុណ្ណោះក្នុងមួយស៊ីឌី។ ដូច្នេះប្រសិនបើប្រិយមិត្តមានចំណាប់អារម្មណ៍ សូមជួយជាវកុំបីខាន។ សូមទំនាក់ទំនងតាមអាសយដ្ឋានខាងក្រោម ឬទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។

សុ មអរគុណ

### អេម៉ាន្យូអែល សំឡេងពីព្រះសហគមន៍កាតូលិក!

ភ្នំពេញ : FM 99.5 Mhz
ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍។

បាត់ដំបង : FM 91.0 Mhz
ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

កំពង់ធំ : FM 107.3 Mhz
ម៉ោង ៥:៣០-៦:០០ រាល់ល្ងាចថ្ងៃសៅរ៍។

កំពង់សោម : FM 100.5 Mhz
ម៉ោង ៧:៣០-៨:០០ ល្ងាចថ្ងៃសៅរ៍។

កំពង់ចាម : FM 100.5 Mhz
ម៉ោង ៩:៣០-១០:០០ យប់ថ្ងៃអាទិត្យ។





## បុណ្យខួបសន្តអ៊ីញ៉ាស់ស៊ីយ៉ូ នៅបាត់ដំបង



Photo: DR

កាលពីថ្ងៃទី៣១ កក្កដា ឆ្នាំ២០០៧ នៅព្រះសហគមន៍បាត់ដំបងមានការប្រារព្ធធ្វើពិធីអភិបូជា នៅវេលាម៉ោង ៦:០០ ល្ងាច ដើម្បីរំឭកដល់ខួបមរណភាពរបស់សន្តអ៊ីញ៉ាស់ស៊ីយ៉ូ ឡូយ៉ាឡា St. Ignatius Loyala ដែលជាស្ថាបនិកនៃក្រុមសហជីវិនព្រះយេស៊ូ Society of Jesus នៅថ្ងៃជាមួយគ្នានោះផងដែរ។

ពិធីនេះមានការចូលរួមពីគ្រីស្តបរិស័ទនៅព្រះសហគមន៍បាត់ដំបង គ្រីស្តបរិស័ទនៅព្រះសហគមន៍តាហែន ព្រមទាំងក្រុមបងប្រុស និងលោកបូជាចារ្យនៃក្រុមសហជីវិនព្រះយេស៊ូជាច្រើននាក់ទៀត។

នេះគឺជាថ្ងៃបុណ្យខួបមរណភាពរបស់សន្តអ៊ីញ៉ាស់ស៊ីយ៉ូ ឡូយ៉ាឡា ដែលមានកំណើតនៅទីក្រុងឡូយ៉ូឡា ភាគខាងជើងនៃប្រទេសអេស្ប៉ាញ នាឆ្នាំ១៤៩១ ហើយទទួលមរណភាពទៅវិញនៅថ្ងៃទី៣១ កក្កដា ឆ្នាំ១៥៥៦ នៅទីក្រុងរ៉ូមប្រទេសអ៊ីតាលី។

លោកបូជាចារ្យតូតែត អ្នកទទួលខុសត្រូវព្រះសហគមន៍បាត់ដំបង និងជាសមាជិកម្នាក់នៃក្រុមសហជីវិនព្រះយេស៊ូដែរនោះ បានមានប្រសាសន៍ថា : “សន្តអ៊ីញ៉ាស់ស៊ីយ៉ូ ឡូយ៉ាឡា គឺជាមនុស្សដែលពូកែបង្ហាត់មនុស្សឱ្យស្គាល់អំពីសេចក្តីស្រលាញ់របស់ព្រះយេស៊ូដែលមានចំពោះមនុស្សលោក។”

ហើយដូចដែលសព្វថ្ងៃនេះ យើងឃើញមានក្រុមសហជីវិនព្រះយេស៊ូមាននៅលើទូទាំងពិភពលោកដូចដែលយើងឃើញមានស្រាប់នៅប្រទេសកម្ពុជាដែរ។

លោកបូជាចារ្យរូបនេះ បន្ថែមទៀតថា : “មានពាក្យស្លោកមួយឃ្លាបានសរសេរថា ចូរស្វែងរកព្រះជាម្ចាស់ក្នុងសកម្មភាពសព្វសារពើ គឺមានន័យថាព្រះជាម្ចាស់មានវត្តមាននៅគ្រប់ទីកន្លែង គ្រប់ពេលវេលា និងគ្រប់ស្ថានភាពទាំងអស់ ទាំងពេលដែលយើងជួបការលំបាក និងពេលយើងសប្បាយ។”

សុជាតិ




Photo: Worl Mission

## សាធារណរដ្ឋទីម័រខាងកើត

ប្រទេសព័រទុយហ្គាល់បានដាក់អាណានិគមលើកោះទីម័រនៅពាក់កណ្តាលសតវត្សរ៍ទី១៦។ លុះមកដល់ថ្ងៃទី២៨ វិច្ឆិកា ឆ្នាំ១៩៧៥ ទីម័រភាគខាងកើតបានប្រកាសឯករាជ្យដោយខ្លួនឯង។ ក្រោយមក ៩ថ្ងៃ កងកម្លាំង ឥណ្ឌូនេស៊ីបានលុកលុយដែនដីនេះ។ នៅខែកក្កដា ឆ្នាំ១៩៧៦ ទីម័រខាងកើត ត្រូវបញ្ចូលជាខេត្តមួយរបស់ឥណ្ឌូនេស៊ី។ នៅថ្ងៃទី៣០ សីហា ឆ្នាំ១៩៩៩ ការធ្វើប្រជាមាតិមួយក្រោមការឃ្លាំមើលពីអង្គការសហប្រជាជាតិ បង្ហាញថា ភាគច្រើនលើសលប់នៃប្រជាជនទីម័រខាងកើតចង់បានឯករាជ្យ។ តែបន្ទាប់មកកងជីវពលទីម័រប្រឆាំងឯករាជ្យភាព បានកកើតឡើង និងទទួលការគាំទ្រពីយោធាឥណ្ឌូនេស៊ី បង្កអំពើហិង្សា និងការសងសឹក។ ជនជាតិទីម័រប្រមាណ១៤០០នាក់ បានស្លាប់ និងប្រមាណ ៣០០ ០០០នាក់ បានភៀសខ្លួនដោយបង្ខំទៅទីម័រខាងលិច។ នៅថ្ងៃទី២០ កញ្ញា ឆ្នាំ១៩៩៩ កងកម្លាំងថែរក្សាសន្តិភាពអន្តរជាតិអូស្ត្រាលី ចូលកាន់កាប់ដែនកោះ និងបញ្ចប់នូវអំពើហិង្សា។ នៅថ្ងៃទី២០ ឧសភា ឆ្នាំ២០០២ ទីម័រខាងកើតត្រូវបានទទួលស្គាល់ជាអន្តរជាតិជារដ្ឋឯករាជ្យ និងក្លាយជាប្រជាជាតិថ្មីបំផុតនៅលើពិភពលោក។

ឯកសារបរទេស

### ទិន្នន័យផ្សេងៗ

ឈ្មោះផ្លូវការ : សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត។ ជនជាតិ : អូស្ត្រូណេស៊ី (អំបូរម៉ាឡាយ៉ូ-ប៉ូលីនេស៊ី) ផាផួន និងក្រុមជនជាតិភាគតិចចិន។ ប្រជាជន : ១ ០៦២ ៧៧៧ នាក់។ ភាសា : ថេធូម និងព័រទុយហ្គាល់ (ផ្លូវការ) ឥណ្ឌូណេស៊ី និងអង់គ្លេស។ សាសនា : រ៉ូម៉ាំងកាតូលិក ៩០% ម៉ូស្លីម ៤% ប្រូតេស្តង់ ៣% ហិណ្ឌូ ០,៥% ពុទ្ធសាសនា និងជំនឿព្រលឹងវិញ្ញាណ។ ផ្ទៃដី : ១៥ ០០៧គម$^2$។ ធនធានធម្មជាតិ : មាស ប្រេង ឧស្ម័នធម្មជាតិ ម៉ង់ហ្គាណែស និងថ្មម៉ាប-ល-។ រូបិយវត្ថុ : ដុល្លារអាមេរិក។ ឯករាជ្យភាព : ថ្ងៃទី២៨ វិច្ឆិកា ឆ្នាំ១៩៧៥ ពីប្រទេសព័រទុយហ្គាល់ និងថ្ងៃទី២០ ឧសភា ឆ្នាំ២០០២ ពីប្រទេសឥណ្ឌូណេស៊ី។







លើឆ្វេង : ការរិះគិត និងពិភាក្សានៅតាមក្រុមតូចៗទៅលើប្រធានបទនៃអង្គសន្និបាត។ លើ : សមាជិក សមាជិការបស់អង្គសន្និបាតនៅពេលសម្រាកពីអង្គប្រជុំ។ ឆ្វេង : អ៊ំប្រាជ្ញាអើយ អាណិតលោកតាអាប្រាហាមផង កុំនាំគាត់ចាក់ក្បាច់ខ្លាំងពេក!



សមាជិក សមាជិកានៃអង្គសន្និបាតរិះគិតក្នុងក្រុមតូចៗ អំពីសកម្មភាពរបស់ព្រះសហគមន៍ ដែលបានធ្វើកន្លងមកក្នុងការបម្រើបងប្អូន អ្នកក្រីក្រ អ្នកជំងឺ និងចាស់ជរា-ល-។

# សន្និបាតព្រះសហគមន៍ភូមិភាគបាត់ដំបង







លើ : ពិធីអធិដ្ឋានដង្ហែព្រះកាយព្រះគ្រីស្តចេញពីអាសនៈ។ ក្រោម : សកម្មភាពចូលរួមលាងចានរបស់សមាជិក សមាជិកា ជាការសម្តែងសមានចិត្តចេះជួយគ្នាទៅវិញទៅមក។





លើឆ្វេង : ក្រុមគណៈកម្មការបាត់ដំបងសម្តែងកាយវិការតាមបទចម្រៀង។ លើ : គណៈកម្មការតំបន់អង្គរសម្តែងការជួយអ្នកជំងឺ។ ឆ្វេង : របាំយុវជនតាហែន។ ស្តាំ : ការចែករូបថតអនុស្សាវរីយ៍ឱ្យអ្នកណែនាំព្រះសហគមន៍។



Photos: L. Sovanna

# ចូរយើងបម្រើគ្នាដោយចិត្តសប្បុរស!

នេះគឺជាប្រធានបទ នៅក្នុងមហាសន្និបាតព្រះសហគមន៍ភូមិភាគបាត់ដំបង។ អង្គមហាសន្និបាតប្រព្រឹត្តទៅ ពីថ្ងៃទី១០ ដល់ ១៣ ខែកក្កដាកន្លងទៅនេះនៅព្រះសហគមន៍បាត់ដំបងក្រុង។នៅក្នុងអង្គសន្និបាតមានការចូលរួម ពីបងប្អូនតំណាងគណៈកម្មការទាំងបីនៃព្រះសហគមន៍ នីមួយៗក្នុងភូមិភាគ ប្រមាណ ១៣០នាក់។

នៅក្នុងអង្គសន្និបាត លោកអភិបាល គីកេ មានប្រសាសន៍ទៅកាន់អ្នកចូលរួម ស្តីអំពីមុខងារអ្នកបម្រើថា: “ភាពជាអ្នកបម្រើ” មានន័យថា អ្វីៗដែលយើងធ្វើ គឺធ្វើដោយសារជំនឿ។ លោកបន្ថែមថា បើយើងចង់ស្គាល់មើលពីជំនឿរបស់ខ្លួន យើងត្រូវមើលអំពីជំនឿរបស់ព្រះយេស៊ូចំពោះព្រះបិតា មើលអំពីព្រះហឫទ័យនៃព្រះយេស៊ូ មើលការរស់នៅរបស់ព្រះយេស៊ូ និងស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ។ លោកសង្កត់ធ្ងន់ថា ជំនឿគឺត្រូវមានការអនុវត្តដោយសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណាដែលចេញមកពីព្រះជាម្ចាស់។

ព្រះសហគមន៍នៅប្រទេសកម្ពុជាបានយកចិត្តទុកដាក់ជាខ្លាំង ដើម្បីអនុវត្តតាមព្រះបន្ទូលរបស់ព្រះយេស៊ូ ដោយបម្រើអ្នកក្រីក្រ អ្នកជំងឺ និងមានបង្កើតនូវសកម្មភាពមនុស្សធម៌ជាច្រើនទៀតផងដែរ។ តើព្រះសហគមន៍ជួយគេយ៉ាងដូចម្តេច ?

លោកបូជាចារ្យហ្វៀរណាន់ មានប្រសាសន៍ថា: “បម្រើបងប្អូនដើម្បីឱ្យមានសេរីភាព ពុំមែនដើម្បីឱ្យគេចូលក្នុងព្រះសហគមន៍នោះទេ”។ ទោះបីយើងខិតខំប្រព្រឹត្តយ៉ាងនេះក្តី បងប្អូនដែលមានមុខងារបម្រើក្នុងព្រះសហគមន៍បានជួបឧបសគ្គយ៉ាងច្រើននៅក្នុងតំបន់ដែលគេរស់នៅ ព្រោះតែការច្រណែន និងភាពលោភលន់នៃមនុស្ស។ ឧបសគ្គទាំងនោះក៏ធ្វើឱ្យបងប្អូនមួយចំនួនធ្លាក់ទឹកចិត្ត ដោយសារការបម្រើព្រះសហគមន៍លំបាក និងគ្មានប្រាក់ខែជាដើម។

បងស្រីលូមីឡា មានប្រសាសន៍លើកទឹកចិត្តក្នុងអង្គប្រជុំដោយសង្កត់ធ្ងន់ពីមុខងារអ្នកបម្រើព្រះសហគមន៍ថា : “យើងគឺជាអ្នកបម្រើត្រូវតែធ្វើជាគំរូល្អ ក្លាហាន មាននូវគោលដៅច្បាស់លាស់ និងក្តីសង្ឃឹម។” នៅក្នុងថ្ងៃនោះដែរ លោកបូជាចារ្យពេទ្រូ ផ្តល់ជូនអង្គប្រជុំ នូវគំនិតមួយ ដែលមាន ១០ចំណុច ស្តីពីចរិតលក្ខណៈនៃការបម្រើរបស់គ្រីស្តបរិស័ទដូចជា សេចក្តីស្រឡាញ់ ការដាក់ខ្លួន សេចក្តីអត់ធ្មត់ សេចក្តីអំណរ ភាពស្មោះត្រង់ ភាពសប្បុរស ភាពសាមញ្ញ ការខំព្យាយាម ការរួមសាមគ្គីគ្នា និងការអធិដ្ឋានដើម្បីជួយលើកទឹកចិត្តដល់បងប្អូន ព្រោះពីដើមរៀងមកអ្នកប្រកាសដំណឹងល្អ អ្នកបម្រើព្រះសហគមន៍ គឺតែងតែមានឧបសគ្គជានិច្ច។

លោកឃឹម ប៉ង់ ដែលមកពីព្រះសហគមន៍ពោធិ៍សាត់ មានប្រសាសន៍ឡើងថា កន្លងមក លោកតែងតែជួបឧបសគ្គច្រើនណាស់ដែរដូចជា នៅពេលចុះជួយបងប្អូនក្នុងភូមិ មានបងប្អូនមួយចំនួនបានចោទថា លោកនិយមបក្សពួក គឺជួយមិនស្មើគ្នាជាដើម។ អ្នកណែនាំរូបនេះ ក៏បន្តថា ពេលខ្លះធ្វើឱ្យលោកធ្លាក់ទឹកចិត្តយ៉ាងខ្លាំង។ ដូចគ្នានេះដែរ អ្នកស្រីឈ្មួន សុខនមានប្រសាសន៍ថា នៅក្នុងភូមិ មានបងប្អូនខ្លះ និយាយមិនល្អ ត្អូះតេះដៀល និងប្រមាថអ្នកស្រីព្រោះតែអ្នកស្រីមានជំនឿលើព្រះយេស៊ូ។ ...

... ចំណែកឯលោកតាំង គួយ បញ្ជាក់ថា: “ជាធម្មតាយើងតែងមានការមិនសប្បាយចិត្ត ឬធ្លាក់ទឹកចិត្ត។” ប៉ុន្តែយើងក៏ត្រូវសួរខ្លួនឯងផងថា តើយើងធ្វើតាមចិត្តយើងប៉ុន្មានភាគរយ? និងធ្វើតាមព្រះបន្ទូលប៉ុន្មានភាគរយ? លោកបន្តថា សូមឱ្យយើងព្យាយាមយកគំរូតាមព្រះនាងម៉ារីដែលស៊ូទ្រាំឈឺចាប់ខ្លាំងណាស់ នៅពេលដែលគេចាប់ព្រះយេស៊ូ យកទៅឆ្កាង។ ព្រះនាងនៅជិតឈើឆ្កាងព្រះយេស៊ូនោះរហូត។

ក្នុងអង្គសន្និបាត ក៏បានរិះគិតផងដែរ អំពីភាពជាអ្នកណែនាំ និងភាពជាអ្នកបម្រើ។ លោកបូជាចារ្យតូតែតបានលើកការប្រៀបធៀបអំពីការឱ្យតម្លៃសម្រាប់អ្នកបម្រើតាមលក្ខណៈសង្គម និងជំនឿថា អ្នកណែនាំ គឺជាអ្នក ដែលមានកិត្តិយសមានឋានៈ វណ្ណៈ និងទ្រព្យសម្បត្តិក្នុងសង្គម រីឯអ្នកបម្រើគឺអ្នកដែលមានឋានៈទាប គ្មានកិត្តិយស និងទ្រព្យសម្បត្តិ។ តើភាពជាអ្នកណែនាំ និងអ្នកបម្រើ មានកិត្តិយស យ៉ាងដូចម្តេច? លោកបូជាចារ្យបញ្ជាក់ថា អ្នកណែនាំ គឺត្រូវបម្រើ។ អ្នកធំត្រូវបម្រើគេ។ ទាំងអស់គ្នាត្រូវធ្វើជាគំរូ។ នេះហើយជាភាពជាអ្នកណែនាំ។ យើងមានកិត្តិយស ដោយបន្ទាបខ្លួនជាអ្នកបម្រើ។ ត្រង់ចំនុចនោះលោកបូជាចារ្យទម្លាប់សុផល បញ្ជាក់ក្នុងអង្គសន្និបាតថា មនុស្សទាំងអស់គឺមានកិត្តិយសនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ព្រោះព្រះជាម្ចាស់បានបង្កើតមនុស្សឱ្យមានលក្ខណៈដូចព្រះអង្គ។ តាមអំពើរបស់មនុស្សមិនអាចធ្វើឱ្យគេបាត់កិត្តិយសនៅចំពោះព្រះភ័ក្ត្រនៃព្រះជាម្ចាស់ឡើយ។ អំពើទាំងនោះគ្រាន់តែរលុបប៉ុណ្ណោះ។ នេះគឺជាហេតុដែលព្រះជាម្ចាស់ចាត់ព្រះយេស៊ូ ឱ្យយាងមកបំពេញ។ “ព្រះជាម្ចាស់ពុំធ្វើឱ្យអ្នកណាម្នាក់វិនាសឡើយ”។ ក្នុងនោះលោកបូជាចារ្យតូតែត បញ្ជាក់អំពីលក្ខណៈនៃអ្នកណែនាំគំរូ ដែលជាអ្នកមានជំនឿ សេចក្តីស្រឡាញ់ ចេះជួយដោយមិនប្រកាន់ប្រយោជន៍ សម្រាប់ខ្លួន មានចិត្តសប្បុរស មានចិត្តរីករាយ និងចិត្តសង្ឃឹម។

អត្ថបទដោយលី សុវណ្ណា

### ភូមិភាគបាត់ដំបង

ក្នុងចំណោមព្រះសហគមន៍ទាំងបីភូមិភាគក្នុងប្រទេសកម្ពុជា ភូមិភាគបាត់ដំបងមានព្រះសហគមន៍ទាំងអស់ចំនួន ២៦ ដែលចែកចេញជា ៤តំបន់ មានដូចជា តំបន់បាត់ដំបង តំបន់អង្គរ តំបន់ទន្លេសាប និង តំបន់កំពង់ធំ ដែលមានគ្រីស្តបរិស័ទបានទទួលអគ្គសញ្ញាជ្រមុជទឹកទាំងអស់ចំនួន ២ ៩៥៥នាក់។

## ចរិតលក្ខណៈនៃការបម្រើរបស់គ្រីស្តបរិស័ទ



Photo: L. Sovanna

១. សេចក្តីស្រឡាញ់ : យើងស្រលាញ់ដោយមិនចាំបាច់គេស្រលាញ់វិញឡើយ។ យើងស្រលាញ់តាមគំរូព្រះយេស៊ូដែលបានបូជាព្រះជន្មសម្រាប់មនុស្សទាំងឡាយ។ សន្តិតេរេសាមានប្រសាសន៍ថា : សេចក្តីស្រលាញ់គឺផ្តល់អ្វីៗទាំងអស់ព្រមទាំងផ្តល់ជីវិតខ្លួនឯងទៀតផង។ ២. ភាពដាក់ខ្លួន : (ម៉ាកុស៩.៣៥) ព្រះយេស៊ូយាងចុះត្រាស់ហៅសាវ័ក ១២រូបមក ហើយមានព្រះបន្ទូលថា : “អ្នកណាចង់ធ្វើមេគេ អ្នកនោះត្រូវដាក់ខ្លួនឱ្យតូចជាងគេព្រមទាំងបម្រើគេទាំងអស់គ្នាផង។” គឺជាការបន្ទាបខ្លួនដោយមិនចង់បានមុខមាត់កិត្តិយស និងឱ្យគេសរសើរនោះឡើយ។ ៣. សេចក្តីអត់ធ្មត់ : (រ៉ូម ១២.១២) “ចូរអត់ធ្មត់ក្នុងពេលមានទុក្ខលំបាក។ ចូរព្យាយាមអធិដ្ឋាន។” ពេលយើងមានឧបសគ្គអ្វីមួយ សូមកុំឱ្យយើងធ្លាក់ទឹកចិត្ត។ យើងត្រូវស៊ូទ្រាំដើម្បីបម្រើអ្នកដទៃ។ ៤. សេចក្តីអំណរ : ពេលយើងបម្រើអ្នកដទៃ ចូរឱ្យយើងមានចិត្តសប្បាយរីករាយដោយទឹកមុខញញឹម។ ៥. ភាពស្មោះត្រង់ : បម្រើអ្នកដទៃដោយមិនគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន។ ៦. ភាពសប្បុរស : (ម៉ាថាយ១០,៨) “ចូរមើលអ្នកជំងឺឱ្យបានជា ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ធ្វើឱ្យមនុស្សឃ្លង់ឱ្យបានជាស្អាតបរិសុទ្ធ។ អ្នករាល់គ្នាបានទទួលអំណាចដោយឥតគិតថ្លៃ ត្រូវជួយគេវិញដោយឥតគិតថ្លៃដែរ។” យើងត្រូវមានចិត្តទូលំទូលាយជួយដល់អ្នកដទៃ និងសុខចិត្តចំណាយពេលវេលាដល់មនុស្សទន់ទាប។ ៧. ភាពសាមញ្ញ : (ម៉ាថាយ ១៨,៤) “អ្នកណាដាក់ខ្លួនដូចក្មេងតូចនេះ អ្នកនោះមានឋានៈធំជាងគេក្នុងព្រះរាជ្យនៃស្ថានបរមសុខ។” យើងត្រូវបំរើគ្នាទៅវិញទៅមកទោះបីជាកិច្ចការដ៏តូចតាចមួយ និងមិនចាំធ្វើអ្វីដែលជាកិច្ចការធំនោះទេ។ ឧទាហរណ៍ : ទៅសួរសុខទុក្ខអ្នកជាប់ឃុំឃាំង។ ៨. ការខិតខំព្យាយាម : (ម៉ាថាយ ៧,៧-៨) “ចូរសុំ ព្រះជាម្ចាស់នឹងប្រទានឱ្យអ្នករាល់គ្នា ចូរស្វែងរក នោះអ្នករាល់គ្នានឹងបានឃើញ ចូរគោះទ្វារ នោះព្រះអង្គនឹងបើកឱ្យអ្នករាល់គ្នាជាពុំខាន ត្បិតអ្នកណាសុំ អ្នកនោះរមែងបានទទួល អ្នកណាស្វែងរកអ្នកនោះរមែងតែងតែបានឃើញ ហើយគេតែងតែបើកទ្វារឱ្យអ្នកដែលគោះ។” យើងត្រូវបំរើគ្នាទៅវិញទៅមកដោយខិតខំព្យាយាមជារៀងរហូត។ ៩. ការរួមសាមគ្គីគ្នា : (១កូរិនថូស ១២,៧) “ព្រះវិញ្ញាណប្រោសប្រទានឱ្យម្នាក់ៗ សម្តែងព្រះអំណោយទានដើម្បីជាប្រយោជន៍រួម” យើងត្រូវបម្រើបងប្អូនឯទៀតៗ ដោយរួបរួមសាមគ្គីគ្នាជាធ្លុងមួយក្នុងព្រះសហគមន៍។ ១០. ការអធិដ្ឋាន : (ម៉ាថាយ៧,២១) ការបម្រើពិតប្រាកដដល់បងប្អូន គឺយើងត្រូវការកម្លាំងពីព្រះជាម្ចាស់ដោយការអធិដ្ឋាន ហើយឱ្យយើងប្រតិបត្តិតាមព្រះហឫទ័យព្រះជាម្ចាស់។





ក្មេងៗប្រមាណជាង១០០នាក់ មកពីទីកន្លែងផ្សេងៗគ្នា ឈរជាជួរៗយ៉ាងមានសណ្តាប់ធ្នាប់។ ក្នុងចំណោមនោះ មានក្មេងកំព្រាជាច្រើននាក់ផងដែរ។ ដូច្នេះហើយយុវជនជុំគីរីមិនព្រងើយកន្តើយឈរអោបដៃមើលនូវការលំបាករបស់ពួកគេឡើយ។

# យុវជនជុំគីរីជួយក្មេងខ្វះភាពកក់ក្តៅ



Photo: M. Kunthear

យុវជនជុំគីរីថតរូបជាមួយនឹងកុមារកំព្រាជាអនុស្សាវរីយ៍

”ឪពុកម្តាយរបស់ខ្ញុំស្លាប់អស់ហើយ ដោយសារផ្ទុកមេរោគអេដស៍ ហើយខ្ញុំមិនដឹងដែរថា ពួកគាត់ស្លាប់តាំងពីពេលណានោះទេ” នេះជាសំដីរបស់កុមារាម្នាក់រូបនៅព្រះសហគមន៍ជុំគីរី ដែលគេមានវ័យទើបតែ ១០ឆ្នាំ។

មានក្មេងប្រមាណជា៣២នាក់ ដែលព្រះសហគមន៍ ក៏ដូចជាយុវជនព្រះសហគមន៍ជុំគីរីកំពុងតែសស្រាក់សស្រាំជួយដល់ពួកគេ។ ពួកគេជាកុមារមកពីគ្រួសារក្រីក្រនិងខ្លះមានឪពុកម្តាយស្លាប់ដោយសារជំងឺអេដស៍។ លោកនាក់ សៅឌី ដែលជាប្រធានក្រុមយុវជនព្រះសហគមន៍ជុំគីរីប្រាប់ថា : “កុមារទាំងនេះមានអាយុពី៦-១៧ឆ្នាំ ហើយអ្នកខ្លះគឺជាក្មេងកំព្រា និងកំពុងរស់នៅជាមួយសាច់ញាតិរបស់គេ។” គាត់បន្ថែមថា ក្មេងៗទាំងអស់នោះមកពីភូមិឆ្ងាយៗ ហើយពួកគេអាចមកព្រះសហគមន៍បាន ដោយសារតែយុវជនបានបែងចែកគ្នាជាក្រុមចុះតាមភូមិដើម្បីស្វែងរកនូវគ្រួសារណា ដែលមានការលំបាកខ្លាំង ជាពិសេសគ្រួសារដែលមានក្មេងកំព្រា។

“ខ្ញុំចាប់អារម្មណ៍ជួយក្មេងទាំងអស់នេះ ដោយសារក្នុងនាមខ្ញុំជាគ្រីស្តបរិស័ទផ្ទាល់ ខ្ញុំទទួលការអប់រំ និងអំណោយទានពីព្រះជាម្ចាស់ ដែលធ្វើឱ្យខ្ញុំដឹងថា ជីវិតអ្នកក្រមានតម្លៃដូចគ្នា។ ដូច្នេះខ្ញុំមានចិត្តមួយ ជួយដល់ក្មេង ដើម្បីឱ្យពួកគេមានសេចក្តីសង្ឃឹមក្នុងការរស់នៅ។” នេះជាសម្តីរបស់លោកឯម សឿន អ្នកសម្របសម្រួលក្រុមយុវជនព្រះសហគមន៍ជុំគីរី។ លោកបន្ថែមថា ការជួយពួកគេ គឺផ្តល់ផលប្រយោជន៍ឱ្យពួកយើងច្រើនដូចជាធ្វើឱ្យយើងយល់ថា ការជួយកូនក្មេងក្រីក្រ និងជួយអ្នកជំងឺ ជាអ្វីមួយដែលយើងជាកូនខ្មែរដូចគ្នា គួរតែចេះជួយគ្នា និងមើលថែគ្នា។ ក្នុងពេលពួកគេមិនមានអ្វីនោះ យើងអាចជួយចែករំលែកអ្វីខ្លះៗឱ្យពួកគេ។

ចំពោះផលលំបាក គឺតែងតែកើតមានទោះបីជាការងារនោះធំ ឬតូចក្តី។ ក្នុងន័យនេះដែរលោកសឿន មានប្រសាសន៍ថា យើងមានផលលំបាកផងដែរ មានជាអាទិ៍ដូចជា យើងមានបំណងជួយពួកគេច្រើន ប៉ុន្តែយើងមិនសូវជាមានថវិកានោះទេ និងម្យ៉ាងយើងមានការខ្វះខាតនូវមធ្យោបាយដើម្បីចុះទៅសួរសុខទុក្ខក្មេងនៅតាមភូមិជាដើម។

នៅទីនោះ មានយុវជនទាំងអស់ចំនួនជាង ៤០នាក់ កំពុងតែមានសកម្មភាពជួយដល់ក្មេងៗកំព្រា ហើយសម្រាប់ការជួយពួកគេ ព្រះសហគមន៍មិនមានលក្ខខណ្ឌអ្វីនោះទេ ហើយនៅក្នុងនោះព្រះសហគមន៍បានជួយពួកគេ ដូចជា សំភារៈសិក្សាសម្លៀកបំពាក់ ការអប់រំអនាម័យ និងនិយាយខ្លះៗ អំពីការលើកទឹកចិត្តដល់ពួកគេផងដែរ។

ប្រសិនបើគ្មានការជួយពីព្រះសហគមន៍ ឬពីយុវជននោះទេ បើតាមលោកឃុត សុខា បាននិយាយឱ្យដឹងផងដែរថា ជីវិតរបស់គេនឹងមិនមានការរីកចម្រើនទេ ដោយសារពួកគេរស់នៅជាមួយជីដូន ឬបងប្អូន ដែលមានជីវភាពក្រីក្រដែរ។

ចំណែកអ្នកស្រីជូ អាន ជាប្រធានគណៈកម្មាការព្រះសហគមន៍ជុំគីរី មានប្រសាសន៍ថា យុវជនយើងបានប្រមូលលុយគ្នាជារៀងរាល់ថ្ងៃអាទិត្យ ជូនដល់គណៈកម្មាការ ដើម្បីជួយដល់ក្មេងៗកំព្រា និងក៏មានជំនួយពីលោកបូជាចារ្យផងដែរ ដោយចំណាយប្រមាណជា ៥០ម៉ឺនរៀល ក្នុង១ខែៗ។

មុំ គន្ធា និងសុខជុំ

### កម្លាំងយុវជន

ទោះបីជាជាមានការលំបាក និងនឿយហត់យ៉ាងណាក៏ដោយ តែក្នុងទឹកចិត្តជាយុវជន-នារីនៅតែពុះពារខិតខំដោយអស់ពីកម្លាំងកាយកម្លាំងចិត្តដើម្បីជួយដល់ជនក្រីក្រ និងជាពិសេសជួយក្មេងៗកំព្រា ដែលកំពុងតែអង្គុយរង់ចាំពួកគេ។ តើអ្វីទៅដែលមានអនុភាពខ្លាំងជាងការរួបរួមសាមគ្គីរវាងគ្នា និងគ្នាទៀតនោះ ? ជាការពិតណាស់ យុវជន គឺជាទំពាំងស្នងឫស្សី ឬជាសរសរទ្រូងរបស់ប្រទេសជាតិ ប៉ុន្តែប្រសិនទំពាំងទាំងនេះមិនប្រើកម្លាំងរបស់ខ្លួនដើម្បីជួយដល់ប្រទេសជាតិទេនោះ តើអនាគតប្រទេសនឹងទៅជាយ៉ាងណាវិញ ?

សម្រាប់វប្បធម៌-អរិយធម៌ខ្មែរដែលបានបន្សល់ទុកជាច្រើនតំណហើយដោយបុព្វបុរសនោះ ប្រជាជនខ្មែរមួយចំនួនធំមិនដឹងពីប្រភពកំណើតរបស់របាំទេពអប្សរនោះឡើយ។ តើរបាំនេះមានប្រភពដូចម្តេច?



Photo: P. Samphy

រូបលំអ : ព្រះសហគមន៍យកចិត្តទុកដាក់បង្រៀនរបាំ

# របាំទេពអប្សរ

របាំទេពអប្សរ ឬអប្សរា ជារបាំមួយដែលសង្គមខ្មែរឱ្យតម្លៃខ្ពស់នៅគ្រប់សម័យកាល។ របាំនេះត្រូវបានទទួលការកោតសរសើរពីមជ្ឈដ្ឋានបរទេសផងដែរ ដោយគេបានចាត់ទុកថារបាំទេពអប្សរ គឺជាតំណាងឱ្យអត្តចរិតដ៏ស្លូតបូតសុភាពរាបសាររបស់ស្ត្រីខ្មែរ។ បើទោះជាយ៉ាងនេះក្តី ក៏គេតែងចង់ដឹងថា របាំទេពអប្សរនេះមានប្រភពចេញពីណាមកដែរ?

តាមប្រភពឯកសារពីនាយកដ្ឋានសិល្បៈទស្សនីយភាពរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានឱ្យដឹងថា ទេពអប្សរ ឬទេពអប្សរបរិវារកញ្ញា ដែលខ្មែរនិយមហៅថា "អប្សរា" គឺជាអ្នករាំរបាំនៅឋានសួគ៌។ ពួកទេពអប្សរនេះកើតឡើងមកពីការកូរសមុទ្រទឹកដោះដើម្បីស្វែងរកទឹកអម្រឹតរវាងពួកសុរៈ (ពួកទេវតា) និងពួកអសុរៈ (ពួកយក្ស) ដែលយកនាគវាសុគីធ្វើជាព្រ័ត្រ។ ការយកនាគវាសុគីធ្វើជាព្រ័ត្រនេះ គឺពួកយក្សទាញខាងក្បាល រីឯពួកទេវតាទាញខាងកន្ទុយនាគ។ ចំណែកឯពួកទេពអប្សរវិញ មានតួនាទីសំខាន់ណាស់ គឺថែរក្សាលោករបស់យើងនេះឱ្យមាននូវបរិយាកាសប្រកបដោយភាពសប្បាយរីករាយ មនោរម្យ និងមានសុភមង្គល។

## វប្បធម៌ខ្មែរ

មត៌កវប្បធម៌ខ្មែរជាកេរដំណែលមួយដែលបានបន្សល់ទុកដោយបុព្វបុរសដូនតាខ្មែរច្រើនសតវត្សរ៍មកហើយ។ ដើម្បីជាការតបស្នងសងគុណចំពោះកេរមត៌កដ៏មានតម្លៃមិនអាចកាត់ថ្លៃបាននេះ ក្នុងនាមយើងជាកូនខ្មែរ គួរចូលរួមថែរក្សាស្នាដៃដែលមានតែមួយនៅលើពិភពលោកដែលនេះក៏បានបង្ហាញអំពីចំណេះដឹងដ៏ប៉ិនប្រសប់នៃប្រជាជនខ្មែរផងដែរ។

ប្រភពឯកសារនេះឱ្យដឹងទៀតដែរថា រូបទេពអប្សរត្រូវបានបុព្វសិល្បករខ្មែរដាប់ឆ្លាក់នៅលើជញ្ជាំងប្រាសាទនានា មានដូចជា ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងលើប្រាសាទជាច្រើនទៀត មានចំនួនស្ទើររាប់មិនអស់ដែលមានតាំងពីឆ្លាក់នៅលើទ្វារ ឬតាមជញ្ជាំងពីខាងក្រោមរហូតដល់ផ្នែកកំពូលនៃប្រាសាទទាំងនោះថែមទៀតផង។

ចំពោះប្រជាជនខ្មែរ អប្សរាមិនគ្រាន់តែជាតួរបាំសួគ៌ប៉ុណ្ណោះទេ តែអប្សរាជាមាតារបស់ខ្លួនថែមទៀតផង។ ទស្សនីយភាពរបាំអប្សរាដែលគេឃើញនៅលើឆាកសព្វថ្ងៃនេះ គឺត្រូវចម្លងចេញពីចម្លាក់នៅអង្គរ។ ហើយការធ្វើឱ្យចម្លាក់បុរាណអប្សរានៅតាមប្រាសាទទាំងឡាយមានសកម្មភាព និងបានរស់ឡើងវិញនៅចំពោះមុខភ្នែករបស់ប្រជាជនខ្មែរនៅគ្រប់ជំនាន់ គឺមានអត្ថន័យសំខាន់ក្រៃលែង។ តួអប្សរាដែលមានសកម្មភាពដ៏រស់រវើក គឺកើតឡើង ដោយសារព្រះរាជតម្រិះរបស់ព្រះមហាក្សត្រីយានីកុសុមៈនារីរតន៍ដែលជាព្រះមាតានៃសម្តេចព្រះករុណាព្រះបាទនរោត្តមសីហនុបច្ចុប្បន្ននេះ។

អ្នកនាំសារ



# ជំងឺក្អកមាន់

អ្នកនាំសារបានចេញផ្សាយអំពីប្រភេទជំងឺជាច្រើនរួចមកហើយ។ សម្រាប់លេខនេះ អត្ថបទសុខភាពនឹងលើកយកជំងឺក្អកមាន់ ដែលតែងធ្វើឱ្យគ្រោះថ្នាក់ និងប៉ះពាល់ដល់កុមារមកបរិយាយម្តង។

បើតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិតឈៀ គន្ធារី ក៏បានឱ្យដឹងថា ជំងឺក្អកមាន់ជាប្រភេទជំងឺឆ្លង ដែលបណ្តាលមកពីមេរោគជាប្រភេទបាក់តេរី។ វាច្រើនកើតមាននៅលើកុមារដែលមានអាយុតិចជាង ៥ឆ្នាំ ហើយរឹតតែធ្ងន់ធ្ងរបំផុតនោះ គឺកើតនៅលើកុមារដែលអាយុតិចជាង ១ឆ្នាំ។ ជំងឺក្អកមាន់នេះច្រើនកើតនៅលើក្មេងដែលហូបពុំគ្រប់គ្រាន់ ខ្វះជីវជាតិអាហារ ខ្វះប្រូតេអ៊ីន និងស្គមរីងរៃជាដើម។

នៅពេលមេរោគឆ្លងចូលទៅក្នុងខ្លួនកុមារ មុនដំបូងគឺវាសម្ងំរយៈពេល ១២ថ្ងៃ បន្ទាប់មកទើបវាបញ្ចេញរោគសញ្ញា ឱ្យឃើញ។ រោគសញ្ញានោះ គឺស្រដៀងនឹងផ្តាសាយដែរ គឺក្អកច្រើនដង តឹងច្រមុះ ហៀរសំបោរ មានស្លេស្ម ហើយមុខ ភ្នែកឡើងក្រហម និងក្នុងភ្នែកមានជាំឈាម។ កុមារអស់កម្លាំង ដេកមិនលក់ ក្អួតមិនឈប់ឈរ ហើយក៏ក្អកជាប់គ្នារងឹក ក្អកម្តងៗ អាចរហូតដល់ ៣០វិនាទីជាប់ៗគ្នារហូត។ អ្វីដែលជាផលលំបាកធំបំផុត គឺកុមារអាចស្លាប់បានដោយសារការក្អកយូរ ធ្វើឱ្យស្អួតខ្សោយ និងស្ទះដង្ហើម ដោយសារមានស្លេស្មច្រើន។ ចំណែកផលវិបាកមួយទៀត គឺវាអាចធ្វើឱ្យអ្នកជំងឺរលាកទងសួត ហើយសួត និងរលាកស្រោមខួរ។ ដូច្នេះ នៅពេលអាណាព្យាបាលឃើញ កុមារក្អកមិនឈប់ជាប់គ្នាច្រើនដង ហើយមុខ ឬមានការស្ទះៗពិបាកក្នុងខ្លួន។ ពួកគាត់ត្រូវប្រញាប់ នាំគេមករកជួបនឹងលោកវេជ្ជបណ្ឌិតជំនាញ ដើម្បីទទួលការព្យាបាលឱ្យទាន់ពេលវេលាពីព្រោះប្រសិនទុកយូរស្ថានភាពជំងឺ គឺអាចឈានទៅដល់អាការៈធ្ងន់ធ្ងរលែងគ្រួតត្រាបាន ពេលនោះអ្នកជំងឺអាចស្លាប់។

ចំពោះការព្យាបាលជំងឺក្អកមាន់ គឺវេជ្ជបណ្ឌិតតែងព្យាបាលទៅតាមរោគសញ្ញា និងការប្រើថ្នាំផ្សះ។ ប៉ុន្តែប្រសើរបំផុតអាណាព្យាបាលគួរនាំកុមារទៅចាក់វ៉ាក់សាំងការពារ។

រតនា



Photo: P. Samphy

វេជ្ជបណ្ឌិតឈៀ គន្ធារី នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

## វ៉ាក់សាំងការពារ

អាណាព្យាបាលគួរយកកូនតូចទៅចាក់វ៉ាក់សាំងការពារក្អកមាន់ជាមួយនឹងវ៉ាក់សាំងខាន់ស្លាក់ និងតេតាណូសដែរ ឱ្យបានគ្រប់ចំនួនដងតាមការបញ្ជារបស់គ្រូពេទ្យ ទើបកុមារពុំកើតជំងឺក្អកមាន់។



# ការធ្វើជីកំប៉ុស្ត

ប្រជាកសិករជាច្រើននៅមិនទាន់ជ្រាបអំពីគុណប្រយោជន៍ជីកំប៉ុស្ត និងតែងត្អូញត្អែរថា ដីស្រែចំការខ្លួនខ្សោះៗ និងគ្មានជីវជាតិ។ ដូច្នេះតើជីកំប៉ុស្តបន្ថែមគុណភាពដី គេធ្វើយ៉ាងដូចម្តេច?



Photo: DR

គេអាចជីករណ្តៅដើម្បីដាក់វត្ថុធាតុធ្វើជីកំប៉ុស្តបំប៉នដីចំការ

ជីកំប៉ុស្ត មានន័យថា ដីមមោក។ នៅជុំវិញមូលដ្ឋានកសិករមានវត្ថុធាតុជាច្រើនណាស់ ដែលអាចយកមកធ្វើជាជីកំប៉ុស្តបាន។ តាមពិតការប្រើជីកំប៉ុស្តនឹងជួយកែលំអរទម្រង់ដី ធ្វើឱ្យដីធូរព្រមទាំងបង្កើនសមត្ថភាពចិញ្ចឹមរបស់ដី។ សារធាតុសរីរាង្គ ដែលមាននៅក្នុងកំប៉ុស្តគឺជាអាហាររបស់អតិសុខុមប្រាណ ដែលមានតួនាទីរក្សានូវសុខភាពដីឱ្យមានតុល្យភាព និងធ្វើឱ្យដំណាំដាំដុះលូតលាស់បានល្អ។

**តើមានវត្ថុធាតុអ្វីខ្លះដែលគេអាចយកមកធ្វើជីកំប៉ុស្តបាន?**

មានដូចជាស្លឹកឈើ ដីល្បប់ ដីមមោក ចំបើង អាចម៍សត្វ-ល-ដោយត្រូវដាក់ជាស្រទាប់ៗ។ កសិករគួរយកដីល្បប់មកដាក់លាយជាមួយអាចម៍សត្វ អាចម៍រណា ផេះ អង្កាម និងសំណល់រលួយស្លឹកឈើនានា។ វត្ថុធាតុស្ទើរតែទាំងអស់អាចយកមកបំពោកក្នុងគំនរកំប៉ុស្តបាន តែដើម្បីកាត់បន្ថយរយៈពេលនៃការពុករលួយរបស់វត្ថុធាតុទាំងនេះចាំបាច់ត្រូវរក្សាអត្រាបរិមាណវត្ថុធាតុពណ៌ប្រផេះ ដែលសម្បូរធាតុកាបោន និងពណ៌បៃតង ដែលសម្បូរធាតុអាហ្សូត ឱ្យបានត្រឹមត្រូវ។ វត្ថុធាតុពណ៌ប្រផេះមានស្លឹកឈើស្ងួត ចំបើង និងកំទេចឈើ រីឯវត្ថុធាតុពណ៌បៃតងច្រើននៅស្រស់ៗ រួមមានកម្ទេចស្មៅ និងសំណល់ផ្ទះបាយ (សំបកឪឡឹក សំបកចេក កម្ទេចបន្លែផ្លែឈើ-ល-)។ យើងអាចដាក់ផេះនៅក្នុងជីកំប៉ុស្តបាន តែកុំដាក់ច្រើនពេកព្រោះធ្វើឱ្យដីប្រៃ។ ដូច្នេះចាំបាច់ គឺគួរដាក់ផេះមួយធុង ៨លីត្រ សម្រាប់គំនរកំប៉ុស្ត ក្នុង១ម៉ែត្រគូប។ អត្រាដែលល្អបំផុតគឺវត្ថុធាតុពណ៌ប្រផេះ ២៥ភាគ ទល់នឹងវត្ថុធាតុពណ៌បៃតង ១ភាគ ដោយប៉ាន់ប្រមាណ តាមទម្ងន់របស់វា។ សន្មត់ថា ក្នុងគំនរកំប៉ុស្តមួយគេ ដាក់ស្លឹកឈើស្ងួត និងចំបើង ២៥គីឡូក្រាម ត្រូវលាយអាចម៍សត្វ ឬសំណល់ពីផ្ទះបាយចំនួនមួយគីឡូក្រាម។

**គួរធ្វើរោងជីកំប៉ុស្តនៅទីណា?**

កំប៉ុស្តរលួយមានក្លិនស្អុយដូច្នេះគួរធ្វើរោងនៅឆ្ងាយពីកន្លែងរស់នៅ។ គំនរកំប៉ុស្តត្រូវតែនៅក្តៅងំ សើមជានិច្ច និងមានដំបូល ឬក្រណាត់កៅស៊ូគ្របការពារភ្លៀង។ កសិករត្រូវធ្វើជីកំប៉ុស្តនៅផ្ទាល់ទៅនឹងដី កុំក្រាលស៊ីម៉ង់ត៍ ដើម្បីឱ្យជន្លេនមីក្រុប និងសត្វល្អិតផ្សេងៗទៀតបានជួយរំលាយ។

អ្នកនាំសារ

## កន្លែងសិក្សា

ប្រសិនបើប្រិយមិត្តមានបំណងចង់សិក្សាអំពីវិធីសាស្ត្រ ឬបច្ចេកទេសកសិកម្មគ្រប់ប្រភេទមានដូចជាចិញ្ចឹមសត្វ ឬដាំដំណាំផ្សេងៗ គឺមានបង្រៀននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជាហៅសេដាក ឬបុគ្គលិករបស់សេដាកអាចទៅបង្រៀនដល់ទីកន្លែងផ្ទាល់តែម្តង ដោយគិតតម្លៃសមរម្យ។ ទំនាក់ទំនងទូរស័ព្ទ : ០២៣ ៨៨០ ៩១៦។

# លោកបូជាចារ្យវិរជ័យ: “ព្រះសហគមន៍ត្រូវមានយុវជន”



Photo: P. Samphy

**លោកបូជាចារ្យស្រីប្រាម៉ុង វិរជ័យ ជាជនជាតិថៃ ដែលគ្រីស្តបរិស័ទភាគច្រើនតែងនាំគ្នាហៅលោកថា លោកថៃៗ។ លោកក្លាយខ្លួនជាបូជាចារ្យនាឆ្នាំ១៩៩២។**

ទោះបីលោកជាជនជាតិថៃមែន តែបើអ្នកដែលពុំធ្លាប់ស្គាល់លោកពេលដែលឃើញ នឹងលាន់មាត់ថា លោកជាជនជាតិខ្មែរ ពីព្រោះទម្រង់មុខរបស់លោកដូចខ្មែរ។ លោកមកប្រទេសកម្ពុជា ដោយចាប់ផ្តើមធ្វើការជាមួយក្រុមយុវជន ទោះបីវាមិនមែនជាចំណាប់អារម្មណ៍របស់លោកក៏ដោយ។

ទាក់ទងនឹងបញ្ហានេះលោកបូជាចារ្យវិរជ័យ មានប្រសាសន៍ប្រាប់អ្នកនាំសារថា: “តាមធម្មតាខ្ញុំមិនចូលចិត្តក្រុមយុវជនទេ ខ្ញុំចូលចិត្តក្រុមចាស់ៗ តែនៅពេលដែលខ្ញុំមកដល់ស្រុកខ្មែរ អត់មាននរណាធ្វើខាងនេះ។ ដូច្នេះខ្ញុំងាកមកចាប់អារម្មណ៍យុវ-ជន-នារីវិញ ដោយសារពួកគេជាកម្លាំងដ៏សំខាន់ដែលធ្វើឱ្យព្រះសហគមន៍ធ្វើដំណើរទៅមុខ។”

ក្រោយសង្គ្រាម មានយុវជនជាច្រើន គ្មាននរណាជួយ ហើយនៅពេលពួកគេចង់និយាយក៏អត់មាននរណាចង់ស្តាប់គេទេ។ មកដល់ត្រង់នេះ លោកក៏បានបញ្ជាក់ថា លោកអាចនិយាយជាមួយពួកគេបាន។ តាមបទពិសោធន៍ជាច្រើនឆ្នាំ ដែលលោកធ្វើការ និងរស់នៅជាមួយយុវជន លោកយល់ថា យុវជនត្រូវការមនុស្សម្នាក់ដែលស្តាប់ពួកគេ និងជួយគេឆ្ពោះទៅមុខ។ លោកបន្តថា បើគ្មានយុវ-ជនព្រះសហគមន៍អាចរីកចម្រើនបាន ប៉ុន្តែវាមិនអាចឈានទៅមុខលឿនបានទេ។ លោកលើកជាឧទាហរណ៍ថា មនុស្សចាស់ដែលកំពុងដើរ គឺពួកគេដើរយឺតៗ អត់មានកម្លាំង ដោយសារតែអាយុច្រើន ប៉ុន្តែចំពោះយុវជន ពួកគេមានកម្លាំងខ្លាំង និងមានស្មារតីរហ័សរហួនផង។ លោកបន្ថែមថា ដើម្បីបង្កើតក្រុមយុវជន គឺត្រូវមានមនុស្សម្នាក់ដែលស្រឡាញ់ពួកគេដោយពិតប្រាកដ មិនថា ជាលោកបូជាចារ្យ ឬក៏បងស្រីនោះទេ។ លោកធ្លាប់មានបទពិសោធន៍ជាមួយនឹងក្រុមយុវជននៅក្នុងប្រទេសកំណើតរបស់លោក។ លោកក៏និយាយឱ្យដឹងខ្លះៗថា ក្រុមយុវជនក្រៅប្រទេស គេអាចដើរដោយខ្លួនឯងបាន ព្រោះគេចេះរួបរួមគ្នា និងមានអ្នកដឹកនាំម្នាក់គួរជឿទុកចិត្ត និងមានសមត្ថភាពពិតប្រាកដដើម្បីចាំលើកទឹកចិត្តពួកគេ។

ជាមួយនិងបញ្ហាខ្លះៗក្នុងការដឹកនាំយុវជន លោកបូជាចារ្យវិរជ័យបញ្ជាក់ថា: “ខ្ញុំចាំបាច់ត្រូវទាក់-ទងជាមួយពួកគេ។ ប៉ុន្តែអ្នកខ្លះថា បូជាចារ្យមិនត្រូវជិតស្និទ្ធជាមួយយុវជនទេ តែខ្ញុំធ្វើមិនបាន ពីព្រោះយុវជនត្រូវការយើងជាកម្លាំងចិត្ត។”

ក្នុងទឹកមុខញញឹម លោកពោលថា យុវជននាឆ្នាំ១៩៩១ និងឆ្នាំ២០០៧ គឺមានលក្ខណៈខុសគ្នា។ ពីមុនមានតែបាល់មួយ គេក៏លេងសប្បាយហើយ តែសម័យនេះទោះមាន១០ ក៏គេពុំចាប់អារម្មណ៍ដែរ។ លោកបូជាចារ្យតាមព្រះសហគមន៍មួយៗគួរចាប់អារម្មណ៍នឹងយុវជន ព្រោះលោកសង្កេតឃើញថា ព្រះសហគមន៍ណា ដែលចាប់អារម្មណ៍យុវជនព្រះសហគមន៍នោះដូចជាមានជីវិត។

មុំ គន្ធា

## ព្រឹត្តិការណ៍សំខាន់!

- ថ្ងៃទី១ ដល់៣១ សីហា: បង្រៀនរបាំក្រុមយុវជននៅព្រះសហគមន៍កំពង់រទេះ។
- ថ្ងៃទី១ សីហា ដល់ទី១៤ កញ្ញា: មានរៀបចំបង្រៀនកូនក្មេងពីថ្នាក់ទី១ ដល់ថ្នាក់ទី៤ នៅភូមិប៉ាង និងនៅកំពង់គោ តំបន់ព្រះសហគមន៍កំពងធំ។
- ថ្ងៃទី១២ សីហា: ពិធីបុណ្យហែព្រះនាងម៉ារីឡើងស្ថានបរមសុខ ជាឧបការីនៃព្រះសហគមន៍បាត់ដំបង។
- ថ្ងៃទី១២ សីហា: ពិធីហែព្រះនាងម៉ារីរៀបចំធ្វើនៅព្រះសហគមន៍ក្រុងសីហនុ។
- ថ្ងៃទី១៣ សីហា: ប្រជុំបូជាចារ្យនៃក្រុងភ្នំពេញអំពីការងារក្នុងព្រះសហគមន៍។
- ថ្ងៃទី១៣-១៥ សីហា: ប្រជុំក្រុមកាយរិទ្ធនៅក្រុងកែប ដែលមកពីព្រះសហគមន៍ចំការទៀង ជុំគីរី និងគីរីវង្ស ដែលមានប្រមាណជាង ៤០០នាក់។
- ថ្ងៃទី១៥ សីហា: ពិធីជ្រមុជទឹកដល់យុវជន ៧នាក់ នៅព្រះសហគមន៍ស្ទួងនៅភូមិភាគកំពង់ចាម។
- ថ្ងៃទី២១ ដល់២៣ សីហា: មហាសន្និ-បាតទូទាំងប្រទេសលើប្រធានបទនិទានរឿងព្រះយេស៊ូក្នុងជីវិតយើង ប្រារព្ធធ្វើនៅព្រះសហគមន៍ផ្សារតូច-ភ្នំពេញ។

## សេចក្តីជូនដំណឹង!

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក មានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និង MP3 និងមានទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងនេះនឹងធ្វើក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទំនាក់ទំនងតាមទូរស័ព្ទ: ០១២ ៣៧៧ ៤៦០។

សូមអរគុណ!

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៨២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ